ការស្តារឡើងវិញនៃភាពពេញលេញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ

ការប្រកាសដល់ពិភពលោកនៃខួបលើកទីពីរឆ្នាំ

គណៈប្រធានទីមួយ
និងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

យើង សូម ប្រកាស ជា ឧឡារិក ថា ព្រះ ស្រឡាញ់ បុត្រាបុត្រីរបស់ទ្រង់ គ្រប់ ជាតិសាសន៍ នៅក្នុង ពិភពលោក នេះ ។ ព្រះ ជា ព្រះបិតា បាន ប្រទានដល់យើងនូវកំណើតដ៏ទេវភាព ជាជីវិតដែលឥតប្រៀបផ្ទឹម និងពលិកម្ម ធួនដ៏និរន្តរ៍នៃ ព្រះរាជបុត្រា សំណព្វរបស់ ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។ ដោយ ព្រះចេស្តានៃព្រះបិតា នោះព្រះយេស៊ូវបានរស់ឡើងវិញម្តងទៀត ហើយបាន ទទួលជ័យជម្នះលើសេចក្តីស្លាប់ ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់យើង ជាគំរូ របស់យើង និងជាព្រះប្រោសលោះរបស់យើង ។

ពីរ រយឆ្នាំ កន្លង ទៅ នៅ ព្រឹក និទាឃរដូវ ដ៏ ស្រស់ស្អាត មួយ ក្នុង ឆ្នាំ ១៨២០ យុវជន យ៉ូសែប ស្ម៊ីធ កំពុង ស្វែងរក ដោយចង់ ដឹង ថា គួរ ចូលរួម ព្រះវិហារ មួយណា គាត់ បាន ចេញ ទៅ ក្នុង ព្រៃ នៅ ជិត ផ្ទះ គាត់ នៅប៉ែកខាងជើង រដ្ឋនូវយ៉ោក សហរដ្ឋអាមេរិក ដើម្បី អធិស្ឋាន ។ គាត់ បាន សួរសំណួរ ទាក់ទង ទៅនឹងសេចក្តីសង្គ្រោះនៃព្រលឹងគាត់ ហើយទុកចិត្តថាព្រះនឹងដឹកនាំគាត់ ។

យើង សូមប្រកាសដោយរាបសាថា នៅក្នុងចម្លើយចំពោះការអធិស្ឋានរបស់ គាត់ ព្រះជាព្រះបិតា និងព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ បានលេចមកជួប យ៉ូសែប ហើយបានផ្តើម « តាំងរបស់ទាំងអស់ឡើងវិញ » (កិច្ចការ ៣:២១) ដូចបានទាយទុកក្នុងព្រះគម្ពីរប៊ីប ។ នៅក្នុងការនិមិត្តនេះ គាត់បានរៀនថា បន្ទាប់ពីការស្លាប់របស់ពួកសាវកជំនាន់ដើម នោះព្រះវិហាររបស់ព្រះគ្រីស្ទក្នុង សញ្ញាថ្មីត្រូវបានបាត់បង់ពីផែនដី ។ យ៉ូសែបនឹងធ្វើជាឧបករណ៍ក្នុងការនាំវា ត្រឡប់មកវិញ ។

យើង សូម អះអាង ថា នៅក្រោម ការ ដឹកនាំ របស់ ព្រះបិតា និង ព្រះរាជបុត្រា នោះ សារទូតសួគ៌ា បាន យាង មក បង្រៀន ដល់ យ៉ូសែប ហើយ បាន ស្ថាបនា សាសនាចក្រ នៃ ព្រះយេស៊ូវគ្រីស្ទ ឡើងវិញ ។ យ៉ូហានបាទីស្ទ ដែល បាន រស់ឡើងវិញ បាន ស្តារ សិទ្ធិអំណាច ដើម្បី ធ្វើពិធី បុណ្យជ្រមុជទឹក ដោយ ការ ពន្លិច សម្រាប់ការផ្តាច់បាប ។ ពួកសាវកបីនាក់ក្នុងចំណោមពួកសាវកដប់ពីរ នាក់កាលពីដើម—ពេត្រុស យ៉ាកុប និងយ៉ូហាន—បានស្តារភាពជាសាវក និង កូនសៅនៃសិទ្ធិអំណាចបព្វជិតភាពឡើងវិញ ។ អ្នកផ្សេងទៀតបានយាងមក ផងដែរ រួម មាន ទាំង អេលីយ៉ា ដែលបានស្តារ សិទ្ធិអំណាច ដើម្បី ចងភ្ជាប់ ក្រុមគ្រួសារជាមួយគ្នាជារៀងរហូតនៅក្នុងទំនាក់ទំនងដ៏អស់កល្បជានិច្ចដែល ហូសពីសេចក្តីស្លាប់ ។

យើងសូមធ្វើជាសាក្សីបន្ថែមថា យ៉ូសែប ស្ម៊ីធ ត្រូវបានប្រគល់អំណោយទាន និង អំណាច នៃ ព្រះ ដើម្បី បកប្រែ កំណត់ត្រា ពី បុរាណ គឺ ព្រះ គម្ពីរ មរមន— សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។ ទំព័រនៃអត្ថបទពិសិដ្ឋនេះ រួមមាន នូវដំណើររឿងនៃការបម្រើដោយផ្ទាល់របស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងចំណោម រាស្ត្រ នៅ អឌ្ឍគោលខាងលិច ភ្លាមៗ បន្ទាប់ពី ការមាន ព្រះជន្ម រស់ឡើងវិញ របស់ទ្រង់ ។ វាបង្រៀនអំពីគោលបំណងនៃជីវិត ហើយពន្យល់អំពីគោលលទ្ធិ នៃព្រះគ្រីស្ទ ដែលសំខាន់ចំពោះគោលបំណងនោះ ។ ជាដៃគូគម្ពីរទៅនឹងគម្ពីរ ប៊ីប ព្រះគម្ពីរមរមនថ្លែងទីបន្ទាល់ថា មនុស្សគ្រប់រូបគឺជាបុត្រាបុត្រីនៃព្រះបិតា សួគ៌ ជា ទីស្រឡាញ់ ថា ទ្រង់ មានផែនការ ដ៏ ទេវភាព សម្រាប់ ជីវិត របស់ យើង ហើយថាព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ មានបន្ទូលនៅសព្វថ្ងៃនេះ ក៏ដូចជាពីជំនាន់មុនដែរ ។

យើងសូមប្រកាសថា សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុង ក្រោយ ដែល បាន រៀបចំឡើង នៅ ថ្ងៃទី ៦ ខែ មេ សា ឆ្នាំ ១៨៣០ គឺជា ព្រះវិហាររបស់ព្រះគ្រីស្ទក្នុងសញ្ញាថ្មីដែលបានស្តារឡើងវិញ ។ សាសនាចក្រ នេះគឺជា យុថ្កា នៅ ក្នុង ជីវិត ដ៏ ឥតខ្ចោះ នៃ ថ្មជ្រុង យ៉ាងឯក គឺ ព្រះយេស៊ូវគ្រីស្ទ និង នៅក្នុង ដង្វាយធួន ដ៏ និរន្តរ៍ និង ការ រស់ឡើងវិញ ដ៏ពិត របស់ទ្រង់ ។ ព្រះ យេស៊ូវគ្រីស្ទបានហៅពួកសាវកជាថ្មីម្តងទៀត ហើយបានប្រគល់សិទ្ធិអំណាច បព្វជិតភាព ដល់ពួកគេ ។ ទ្រង់ អញ្ជើញ យើង ទាំងអស់ គ្នា ឲ្យ មក រកទ្រង់ និង សាសនាចក្រ របស់ ទ្រង់ ដើម្បី ទទួល ព្រះវិញ្ញាណបរិសុទ្ធ ពិធីបរិសុទ្ធ នៃ សេចក្តីសង្គ្រោះ និងដើម្បីទទួលបានអំណរដ៏ខ្ជាប់ខ្ជួន ។

ពីរ រយឆ្នាំ បាន កន្លង ហួស ទៅ ហើយ ចាប់តាំង ពី ការស្តារ ឡើងវិញ ត្រូវ បាន ចាប់ផ្តើម ដោយ ព្រះ ជា ព្រះបិតា និង ព្រះរាជបុត្រា សំណព្វ របស់ទ្រង់ គឺ ព្រះយេស៊ូវគ្រីស្ទ ។ មានមនុស្សរាប់លាននាក់នៅទូទាំងពិភពលោក បានឱប ក្រសោបយកចំណេះដឹងមួយនៃព្រឹត្តការណ៍ដែលបានព្យាករទុកទាំងនេះ ។

យើង រីករាយ នឹង ប្រកាស ថា ការស្តារឡើងវិញ ដែលបាន សន្យា នោះ បន្ត ឆ្ពោះទៅមុខតាមរយៈវិវរណៈជាបន្តបន្ទាប់ ។ ផែនដី នឹង ពុំ នៅ ដដែលឡើយ នៅពេលព្រះនឹង « បំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ » (អេភេសូរ ១:១០) ។

ដោយ គារវភាព និងការ ដឹងគុណ ពួកយើងជា សាវក របស់ទ្រង់ សូមអញ្ជើញ មនុស្ស ទាំងអស់ ឲ្យបាន ដឹង—ដូចជា យើងបានដឹង—ថា ស្ថានសួគ៌ បានបើក ។ យើង អះអាង ថា ព្រះ កំពុង បង្ហាញ ព្រះឆន្ទៈ របស់ទ្រង់ ចំពោះ បុត្រាបុត្រី ជា ទីស្រឡាញ់ របស់ទ្រង់ ។ យើង ថ្លែង ទីបន្ទាល់ ថា អស់ អ្នក ដែល សិក្សា សារលិខិត អំពី ការ ស្តារឡើងវិញ នេះ ប្រកប ដោយ ការ អធិស្ឋាន ហើយ ធ្វើ សកម្មភាព ដោយជំនឿ នឹង ត្រូវ ប្រទានពរ ឲ្យ ទទួល បាន សាក្សី ផ្ទាល់ខ្លួន អំពី ទេវភាព និង គោលបំណង របស់ វា នៅ ក្នុង ការរៀបចំ ពិភពលោក សម្រាប់ ការយាង មក ជាលើក ទីពីរ របស់ព្រះអម្ចាស់ និង ព្រះអង្គសង្គ្រោះ ព្រះយេស៊ូវ គ្រីស្ទរបស់យើង ដូចដែលបានសន្យា ។

ការប្រកាសនេះត្រូវបានអានដោយប្រធាន រ័សុល អិម ណិលសុន
ជាផ្នែកមួយនៃសារលិខិតរបស់លោកនៅក្នុងសន្និសីទទូទៅប្រចាំឆ្នាំលើកទី ១៩០
នៅថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០២០ នៅក្នុងទីក្រុងសលត៍ លេក រដ្ឋយូថាហ៍ ។

Unofficial poster layout of the text published on churchofjesuschrist.org. Not an official publication of The Church of Jesus Christ of Latter-day Saints. Generated by Urim, urim.samuelbaird.com